ព្រះរាជាណាចក្រកម្ពុជា

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ : ៥៧ ក្រ

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨២ ។

# សំរេច

ប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញនិងនាំចូលដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩ នាសម័យប្រជុំសាមញ្ញលើទី១៧ នីតិកាលទី១ ។

ធ្វើនៅភ្នំពេញ.ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់
## ស្តីពី
## ពន្ធលើទំនិញនាំចេញ និង នាំចូល

## ជំពូកទី១
### បទបញ្ញត្តិទូទៅ

*មាត្រា១* : ត្រូវបានបង្កើតពន្ធលើទំនិញនាំចេញ និង នាំចូល ដើម្បីជាផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និងរួមចំណែកក្នុងថវិកាជាតិ ។

*មាត្រា២* : ការត្រួតពិនិត្យ និង ការប្រមូលពន្ធលើទំនិញនាំចេញនិងនាំចូលជាសមត្ថកិច្ចរបស់អង្គការគយ និងរដ្ឋាករ ក្រោមការដឹកនាំ និង គ្រប់គ្រងផ្ទាល់របស់ក្រសួងហិរញ្ញវត្ថុ ។

*មាត្រា៣* : ម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញដែលជាប់ពន្ធត្រូវបង្កការងាយស្រួលឱ្យការត្រួតពិនិត្យនិងការប្រមូលពន្ធ ប្រព្រឹត្តទៅតាមការកំណត់នៃច្បាប់នេះ ។

*មាត្រា៤* : ត្រូវហាមឃាត់ការគេចវេះមិនបង់ពន្ធ ការបន្លំពន្ធនាំចេញនិងនាំចូល ការដឹកជញ្ជូនទំនិញហាមឃាត់ ការនាំចេញនិងនាំចូល នូវទំនិញដែលរដ្ឋហាមឃាត់ក្នុងការនាំចេញ និងនាំចូលការធ្វើឱ្យរាំងស្ទះ ឬ ការប្រឆាំងនឹងការត្រួតពិនិត្យការប្រមូលពន្ធរបស់អង្គការគយ និងរដ្ឋាករ ។

## ជំពូកទី២
### បែបបទនៃការប្រមូលពន្ធលើទំនិញ
### នាំចេញនិងនាំចូល

*មាត្រា៥* : ពន្ធលើទំនិញនាំចេញនិងនាំចូលចែកជាពីរប្រភេទ :

១_ ពន្ធលើទំនិញនាំចេញ និង នាំចូល ដើម្បីអាជីវកម្ម ។

២_ ពន្ធលើទំនិញនាំចេញនិងនាំចូល ដែលគ្មានលក្ខណៈពាណិជ្ជកម្ម ។

*មាត្រា៦* : ក្រុមប្រឹក្សារដ្ឋមន្ត្រីនឹងកំណត់មុខទំនិញនាំចេញនិងនាំចូល ដើម្បីអាជីវកម្ម និង មុខទំនិញនាំចេញនិងនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម ដែលត្រូវហាមឃាត់ ។

*មាត្រា៧* : ពន្ធលើទំនិញនាំចេញ នាំចូលទាំងពីរប្រភេទដូចបានកំណត់ក្នុងមាត្រា៥ ត្រូវប្រមូលតាម

តំលៃទំនិញ " ហៅថាថ្លៃគិតពន្ធ " និងតាមអត្រាពន្ធដែលមានក្នុងតារាងពន្ធពីរភ្ជាប់ជាឧបសម្ព័ន្ធជាមួយច្បាប់នេះ ។

- *តារាងទី១* : ប្រើចំពោះទំនិញនាំចេញនិងនាំចូលដើម្បីអាជីវកម្ម ។ តារាងនេះមានអត្រាពន្ធ ២ ប្រភេទ :

  ក_ អត្រាពន្ធអប្បបរមាប្រើចំពោះករណីនាំចូលផលិតផលនៃប្រទេស ដែលបានទទួលស្គាល់រដ្ឋកម្ពុជា ករណីអនុគ្រោះផ្សេងៗដែលក្រុមប្រឹក្សារដ្ឋមន្ត្រីសំរេច និង ករណីនាំចេញទៅប្រទេសខាងលើ ។

  ខ_ អត្រាពន្ធទូទៅប្រើចំពោះករណីនាំចូលផលិតផលរបស់ប្រទេសផ្សេងៗ និង ករណីនាំចេញទៅប្រទេសផ្សេងៗ ក្រៅពីប្រទេសដែលពោលក្នុងចំណុច " ក " ខាងលើ ។

- *តារាងទី២* : ប្រើចំពោះទំនិញនាំចេញនិងនាំចូល គ្មានលក្ខណៈពាណិជ្ជកម្ម ។

ផ្អែកតាមតារាងពន្ធក្នុងច្បាប់នេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីកំណត់អត្រាពន្ធជាក់ស្តែងតាមប្រភេទទំនិញនីមួយៗ ដើម្បីអនុវត្តក្នុងរយៈពេលនីមួយៗ ។

*មាត្រា៨* : ថ្លៃគិតពន្ធលើទំនិញនាំចេញនិងនាំចូល គឺថ្លៃលក់ដុំ ( មិនទាន់មានពន្ធលើទំនិញនាំចេញនិងនាំចូល ) លើទីផ្សារនៅមាត់ច្រក ។

ក្រសួងហិរញ្ញវត្ថុនឹងកំណត់ថ្លៃគិតពន្ធលើមុខទំនិញនីមួយៗឱ្យបានសមស្រប និង ថ្លៃទំនិញនៅទីផ្សារដែលប្រែប្រួល ។

*មាត្រា៩* : ការបន្ថយ ការលើកលែងពន្ធលើទំនិញនាំចេញនិងនាំចូល និងត្រូវកំណត់ដូចខាងក្រោម :

១_ ត្រូវបានបន្ថយពន្ធ ចំពោះទំនិញដែលដឹកជញ្ជូនលើកដាក់ដែលខូចខាត បាត់បង់មានមូលហេតុត្រឹមត្រូវដែលបានអង្គការមានសមត្ថកិច្ចបញ្ជាក់ទទួលស្គាល់ ។

២_ ត្រូវបានលើកលែងពន្ធក្នុងករណី :

  ក_ ទំនិញនាំចូលបណ្តោះអាសន្ន ហើយត្រូវនាំចេញទៅវិញ និង ទំនិញនាំចេញបណ្តោះអាសន្នហើយនាំចូលមកវិញ ដើម្បីតាំងពិព័រណ៍ និងផ្សព្វផ្សាយពាណិជ្ជកម្ម ។

  ខ_ ទំនិញដឹកជញ្ជូនឆ្លងកាត់ ឬ ខ្ចីផ្លូវឆ្លងប្រទេសកម្ពុជា ។

  គ_ ទំនិញរបស់ពលរដ្ឋកម្ពុជា ដែលរដ្ឋចាត់តាំងទៅបំពេញការងារ ឬ រៀនសូត្រនៅបរទេស ដែលយកចំណូលសមស្របរបស់ខ្លួនទិញយកមក ឬ ផ្ញើមកឱ្យគ្រួសារ ។

  ឃ_ ជំនួន អំណោយនាំចេញ និង នាំចូល របស់អង្គការសមាគម ឬ របស់ប្រតិភូជាផ្លូវការ ។

  ង_ ទំនិញរបស់ប្រជាជននៅព្រំដែនផលិតបានដែលផ្លាស់ប្តូរប្រចាំថ្ងៃ ជាមួយប្រជាជននៅព្រំដែននៃប្រទេសជិតខាង ក្នុងកំរិតដែលក្រសួងហិរញ្ញវត្ថុកំណត់ ។

ការបន្ថយ ការលើកលែងពន្ធ ក្រៅពីចំណុចទី១ និងទី២ នៃមាត្រានេះ គឺអាស្រ័យដោយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុជាអ្នកសំរេច ។

ចំពោះទំនិញដែលបានបន្ថយពន្ធ ឬ លើកលែងពន្ធដូចពោលខាងលើ ប៉ុន្តែក្រោយមកបើមូលហេតុបន្ថយ ឬ លើកលែង មានការផ្លាស់ប្តូរផ្សេងពីការកំណត់នោះនឹងត្រូវប្រមូលពន្ធលើទំនិញនាំចូល និង នាំចេញគ្រប់ចំនួនវិញ ។

ក្រសួងហិរញ្ញវត្ថុនឹងកំណត់ពីសមត្ថកិច្ច និង បែបបទពិនិត្យការបន្ថយ ការលើកលែងពន្ធ និង ការប្រមូលពន្ធគ្រប់ចំនួនវិញ ។

*<u>មាត្រា១០</u>* : ពន្ធលើទំនិញនាំចេញនិងនាំចូល ប្រមូលតែមួយដងគត់ ។ ទំនិញដែលបានបង់ពន្ធនាំចេញនិងនាំចូលរួចហើយ ត្រូវមានបង្កាន់ដៃបង់ពន្ធ ឬ លិខិតអនុញ្ញាតឱ្យដឹកជញ្ជូន ស្តុកទុក ដែលអង្គការគយ និងរដ្ឋាករចេញឱ្យភ្ជាប់ជាមួយ ។

*<u>មាត្រា១១</u>* : ការត្រួតពិនិត្យ និង ការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញនិងនាំចូល ត្រូវអនុវត្តនៅតាមតំបន់ត្រួតពិនិត្យ និងទីកន្លែងត្រួតពិនិត្យដែលបានកំណត់ ។

ក្នុងតំបន់ត្រួតពិនិត្យ និង ក្នុងកន្លែងត្រួតពិនិត្យដែលបានកំណត់ ទំនិញដែលបានបង់ពន្ធរួចហើយត្រូវមានលិខិតស្របច្បាប់ដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ ។

ក្រៅតំបន់ត្រួតពិនិត្យ និង ក្រៅទីកន្លែងត្រួតពិនិត្យដែលបានកំណត់ ទំនិញនាំចូល មិនចាំបាច់មានលិខិតស្របច្បាប់ ដូចពោលខាងលើភ្ជាប់ជាមួយទេ លើកលែងតែប្រភេទទំនិញមួយចំនួន ដែលត្រូវមានលិខិតស្របច្បាប់បញ្ជាក់ថា ទំនិញទាំងនោះបានបង់ពន្ធរួចហើយ ។

ក្នុងករណីទាំងពីរខាងលើ បើគ្មានលិខិតស្របច្បាប់បញ្ជាក់ថា ទំនិញទាំងនោះបានបង់ពន្ធនាំចេញ ឬ នាំចូលរួចហើយទេនោះ ម្ចាស់ទំនិញត្រូវចាប់ឱ្យបង់ពន្ធ និងត្រូវទទួលការផ្តន្ទាទោស តាមបទបញ្ញត្តិនៃច្បាប់នេះ ។

*<u>មាត្រា១២</u>* : ក្រសួងហិរញ្ញវត្ថុកំណត់ :

- តំបន់ត្រួតពិនិត្យ និង កន្លែងត្រួតពិនិត្យ លើកលែងតែកន្លែងត្រួតពិនិត្យលើផ្លូវគមនាគមន៍ដែលត្រូវមានការឯកភាពពីក្រុមប្រឹក្សារដ្ឋមន្ត្រីជាមុន ។
- ប្រភេទទំនិញនាំចូលមួយចំនួន ដែលនៅក្រៅតំបន់ត្រួតពិនិត្យ និង ក្រៅកន្លែងត្រួតពិនិត្យដែលត្រូវមានបង្កាន់ដៃបង់ពន្ធ ឬលិខិតអនុញ្ញាតឱ្យដឹកជញ្ជូន ស្តុកទុក ភ្ជាប់ជាមួយ ។

# ជំពូកទី៣

## ភារកិច្ចរបស់អ្នកនាំទំនិញចេញនិងនាំទំនិញចូល

*<u>មាត្រា១៣</u>* : ម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញដែលមានទំនិញត្រូវជាប់ពន្ធនាំចេញនិងនាំចូល មានភារកិច្ចដូចខាងក្រោម :

១- អនុវត្តឱ្យបានត្រឹមត្រូវ តាមការកំណត់របស់រដ្ឋ អំពីបែបបទនាំចេញ ឬ នាំចូលមុខទំនិញ និងអំពីទីកន្លែងដែលអនុញ្ញាតឱ្យនាំចេញ ឬនាំចូល ។

២- អនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់របស់អង្គការគយនិងរដ្ឋាករ អំពីការធ្វើប្រតិវេទន៍ ការថែរក្សាបញ្ជីគណនេយ្យ ការបង់ពន្ធ និង បង់ពិន័យ (បើមាន) អំពីបែបបទដឹកជញ្ជូន លក់ដូរ និង ស្តុកទុកទំនិញ។ ក្នុង

ករណីមានការតវ៉ា អំពីចំនួនប្រាក់ពន្ធឬប្រាក់ពិន័យនោះ ក្នុងពេលរង់ចាំការដោះស្រាយបណ្តឹងតវ៉ាម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញ ត្រូវតែបង់ឱ្យបានគ្រប់ចំនួន នូវប្រាក់ពន្ធឬប្រាក់ពិន័យ តាមការកំណត់របស់អង្គការគយ និងរដ្ឋាករ ។

# ជំពូកទី៤

## សិទ្ធិនិងភារកិច្ចរបស់អង្គការគយនិងរដ្ឋាករ

<u>មាត្រា១៤</u> : ក្នុងពេលបំពេញភារកិច្ចប្រមូលពន្ធ កម្មាភិបាល បុគ្គលិកគយនិងរដ្ឋាករ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ មានលិខិតសំគាល់ខ្លួនភ្ជាប់ជាមួយ ។

ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវការកំណត់របស់រដ្ឋ ស្តីពីការប្រមូលប្រាក់ បង់ប្រាក់ចូលថវិកា ស្តីពីការឆែកពិនិត្យ ឃាត់ទុកបណ្តោះអាសន្ន ថែរក្សាទំនិញ សំរេចពីវត្ថុតាងល្មើសច្បាប់ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ឯកសារបោះពុម្ព ដើម្បីប្រមូលពន្ធ ។

<u>មាត្រា១៥</u> : ក្នុងពេលបំពេញភារកិច្ច កម្មាភិបាល បុគ្គលិកគយនិងរដ្ឋាករ មានសិទ្ធិដូចតទៅ :

១_ ណែនាំម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញឱ្យធ្វើប្រតិវេទន៍ទំនិញ ត្រួតពិនិត្យទំនិញគិតពន្ធ និង ប្រមូលពន្ធ តាមអត្រាពន្ធនិងថ្លៃគិតពន្ធដែលបានកំណត់ ។

២_ ត្រួតពិនិត្យទំនិញ និងមធ្យោបាយដឹកជញ្ជូនទំនិញនៅកន្លែងត្រួតពិនិត្យនៅតាមមាត់ច្រក នៅតាមកំពង់ផែ ព្រលានយន្តហោះ ស្ថានីយរថភ្លើង ចំណតរថយន្ត ត្រួតពិនិត្យទំនិញនាំចេញ ឬ នាំចូលធ្វើជាប្រអប់នៅតាមប្រៃសណីយ៍ ។

៣_ ត្រួតពិនិត្យទំនិញនៅតាមឃ្លាំងទំនិញ និង នៅតាមបណ្តាអាជីវកម្មដ្ឋានទំនិញនាំចេញ និង នាំចូលដែលស្ថិតក្នុងមុខសញ្ញាអង្គការគយនិងរដ្ឋាករ គ្រប់គ្រង ។

៤_ ក្នុងករណីមានបទល្មើសជាក់ស្តែង អាចត្រួតពិនិត្យឆែកឆេរលំនៅដ្ឋានតាមបទបញ្ញត្តិស្តីពីការឆែកឆេរលំនៅដ្ឋានរបស់ប្រជាជន ។

៥_ ក្នុងតំបន់ត្រួតពិនិត្យ និង ក្នុងកន្លែងត្រួតពិនិត្យទាមទារឱ្យម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញផ្តល់លិខិតស្នាមចាំបាច់ដែលបញ្ជាក់ថា ទំនិញទាំងនោះ បានបង់ពន្ធនាំចេញឬនាំចូលរួចហើយ ។

ក្រៅតំបន់ត្រួតពិនិត្យ និង ក្រៅកន្លែងត្រួតពិនិត្យ ទាមទារឱ្យម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញ ផ្តល់លិខិតស្នាមចាំបាច់ ចំពោះប្រភេទទំនិញមួយចំនួនដែលត្រូវមានលិខិតស្នាមចាំបាច់ដែលបញ្ជាក់ថាទំនិញទាំងនោះបានបង់ពន្ធនាំចេញ ឬនាំចូលរួចហើយ ។

៦_ ធ្វើកំណត់ហេតុ ក្នុងករណីល្មើសនឹងច្បាប់ពន្ធលើទំនិញនាំចេញ និងនាំចូល ឃាត់ទុកជាបណ្តោះអាសន្ននូវទំនិញល្មើសច្បាប់និង មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើស ។

*មាត្រា១៦* : សមត្ថកិច្ចដោះស្រាយការល្មើសច្បាប់ពន្ធលើទំនិញនាំចេញ និង នាំចូល ត្រូវកំណត់ដូចតទៅ :

១_ ទីស្នាក់ការគយនិងរដ្ឋាករ មានសិទ្ធិពិន័យជាប្រាក់ដល់ ៥.០០០៖០០ ឃាត់ទុកទំនិញដែលមានតម្លៃដល់ ៥.០០០៖០០ ។

២_ សាខា ទីចាត់ការគយ និងរដ្ឋាករ មានសិទ្ធិពិន័យជាប្រាក់ដល់ ៣០.០០០៖០០ ឬ ឃាត់ទុកទំនិញដែលមានតម្លៃដល់ ៣០.០០០៖០០ ។

៣_ ទីចាត់ការគយនិងរដ្ឋាករ មានសិទ្ធិពិន័យជាប្រាក់ចាប់ពី ២០០៖០០ ឡើងទៅ ឬឃាត់ទុកទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ផ្ទាល់សំរាប់ប្រព្រឹត្តល្មើស មានតម្លៃចាប់ពី ២០០៖០០ ឡើងទៅ ។

៤_ អង្គការគយនិងរដ្ឋាករ អាចសំរេចលក់ទំនិញដែលឃាត់ទុកហើយឆាប់ខូចគុណភាព ទុកយូរមិនបានដោយមានការឯកភាពពីថ្នាក់លើផ្ទាល់ ។

៥_ ក្នុងករណីមានការរឹបអូសទំនិញ ឬ មធ្យោបាយដឹកជញ្ជូន ត្រូវបញ្ជូនសំណុំរឿងទៅតុលាការដើម្បីសំរេច ។

*មាត្រា១៧* : សមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ា អំពីពន្ធលើទំនិញនាំចេញ និង នាំចូល ត្រូវកំណត់ដូចតទៅ :

- ការតវ៉ាលើសេចក្តីសំរេចអំពីពន្ធពិន័យ ការឃាត់ទុកទំនិញរបស់ស្នាក់ការគយនិងរដ្ឋាករ ត្រូវសាខា ទីចាត់ការគយនិងរដ្ឋាករ ពិនិត្យនិងសំរេច ។
- ការតវ៉ាលើសេចក្តីសំរេចអំពីពន្ធ ពិន័យ ការឃាត់ទុកទំនិញរបស់សាខាគយនិងរដ្ឋាករ ត្រូវទីចាត់ការគយនិងរដ្ឋាករ ពិនិត្យនិងសំរេច ។
- ការតវ៉ាលើសេចក្តីសំរេចអំពីពន្ធ ពិន័យ ការឃាត់ទុកទំនិញ ឬ មធ្យោបាយរបស់ទីចាត់ការគយនិងរដ្ឋាករ ត្រូវក្រសួងហិរញ្ញវត្ថុពិនិត្យនិងសំរេច ។
- សេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គឺជាសេចក្តីសំរេចចុងបញ្ចប់ ។

*មាត្រា១៨* : កម្មាភិបាល ឬ បុគ្គលិកគយនិងរដ្ឋាករ ដែលសំរេចភារកិច្ចបានស្នាដៃល្អនឹងត្រូវបានទទួលរង្វាន់តាមរបបកំណត់របស់ក្រសួងហិរញ្ញវត្ថុ ។

* រដ្ឋអំណាចមូលដ្ឋាននានា កងកម្លាំងប្រដាប់អាវុធ ត្រូវជួយដល់កម្លាំងក្នុងការត្រួតពិនិត្យបទល្មើស លើទំនិញនាំចេញ ឬ នាំចូល ក្នុងករណីដែលអង្គការគយនិងរដ្ឋាករស្នើសុំ ។
* រដ្ឋអំណាចមូលដ្ឋាននានា កងកម្លាំងប្រដាប់អាវុធ ឬពលរដ្ឋណាដែលមានស្នាដៃជួយអង្គការគយនិងរដ្ឋាករ ក្នុងការអនុវត្តន៍ច្បាប់នេះ ត្រូវបានទទួលរង្វាន់តាមការកំណត់របស់ក្រសួងហិរញ្ញវត្ថុ ។

# ជំពូកទី៥

## ទោសបញ្ញត្តិ

មាត្រា១៩ : ជនណាប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដោយយោលទៅលើលក្ខណៈនៃអំពើល្មើសត្រូវព្រមាន ពិន័យជាប្រាក់ រឹបអូសទំនិញ មធ្យោបាយដឹកជញ្ជូន ឬ ដាក់ពន្ធនាគារ ។

ការរឹបអូសវត្ថុតាង ជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា២០ : ម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញ ដែលអនុវត្តមិនបានត្រឹមត្រូវ តាមបញ្ញត្តិមាត្រា១៣ នៃច្បាប់នេះ ត្រូវព្រមាន ឬ ពិន័យជាប្រាក់ ២០០៖០០ ដល់ ២.០០០៖០០ ។ ក្នុងករណីប្រព្រឹត្តល្មើសច្រើនដង ឬ បានប្រព្រឹត្តល្មើសមានលក្ខណៈធ្ងន់ធ្ងរ ត្រូវពិន័យជាប្រាក់រហូតដល់ ៥.០០០៖០០ ។

មាត្រា២១ : ជនណាមានសកម្មភាពគេចវេះ ឬ បន្លំពន្ធលើទំនិញនាំចេញនិងនាំចូល អាចត្រូវផ្តន្ទាទោសពិន័យរហូតដល់ ២ដង លើប្រាក់ពន្ធដែលគេចវេះ ឬបន្លំ ។

ក្នុងករណីប្រព្រឹត្តច្រើនដង អាចត្រូវផ្តន្ទាទោសពិន័យរហូតដល់ ៥ដង លើប្រាក់ពន្ធដែលគេចវេះ ឬ បន្លំ ។ ក្រៅពីការបង់ប្រាក់ពិន័យ ជនល្មើសត្រូវបង់ឱ្យគ្រប់ចំនួន នូវប្រាក់ពន្ធដែលខ្លួនបានគេចវេះ ឬបន្លំនោះថែមទៀត ។

ក្នុងករណីដែលសកម្មភាពគេចវេះ ឬ បន្លំពន្ធមានលក្ខណៈធ្ងន់ធ្ងរ ឬមានការចាត់តាំង ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ដល់ ៣ឆ្នាំ ។ ឯទំនិញ និង មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់សំរាប់ប្រព្រឹត្តអំពើនេះ ត្រូវរឹបអូស ។

មាត្រា២២ : ម្ចាស់ទំនិញ ឬ តំណាងម្ចាស់ទំនិញដែលបង់ពន្ធ ឬបង់ពិន័យមិនត្រូវតាមរយៈពេលដែលអង្គការគយនិងរដ្ឋាករ បានកំណត់ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវបង់បន្ថែម ១ភាគរយ ក្នុងមួយថ្ងៃ លើចំនួនប្រាក់ដែលបង់យឺតយូរនោះ ។

ក្នុងករណីម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញមិនបង់ពន្ធ ឬបង់ពិន័យទេនោះ ទំនិញនិងមធ្យោបាយដឹកជញ្ជូនដែលបានឃាត់ទុកជាបណ្ដោះអាសន្ន ដើម្បីធានាប្រាក់ពន្ធ ឬ ប្រាក់ពិន័យនោះ នឹងត្រូវរឹបអូស ។

មាត្រា២៣ : ជនណានាំចេញឬនាំចូល ដឹកជញ្ជូន ស្តុកទុក លក់ដូរទំនិញហាមឃាត់ ដោយយោលទៅតាមលក្ខណៈនៃបទល្មើស ត្រូវផ្តន្ទាទោសដូចខាងក្រោម :

- រឹបអូសទំនិញ

រឹបអូសទំនិញ និង មធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើស ។

ជនល្មើសត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ខែ ដល់ ១០ ឆ្នាំនិង រឹបអូសទំនិញ និង មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើស ។ ក្នុងករណីធ្ងន់ធ្ងរជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ដល់ ២០ ឆ្នាំ ។

មាត្រា២៤ : ជនណានាំចេញឬនាំចូល នូវទំនិញដែលរដ្ឋហាមឃាត់ក្នុងការនាំចេញនិងនាំចូល ដោយឃាលទៅតាមលក្ខណៈនៃអំពើល្មើស ត្រូវផ្តន្ទាទោសដូចខាងក្រោម :

- រឹបអូសទំនិញ
- រឹបអូសទំនិញ និង មធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើស ។
- ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ដល់ ៥ ឆ្នាំ ។
- ក្នុងករណីធ្ងន់ធ្ងរ ជនល្មើសអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ ។

ឯទំនិញ និង មធ្យោបាយដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើសនេះ ត្រូវរឹបអូស ។

ក្នុងករណីខាងលើនេះ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការដើម្បីសំរេច ។

មាត្រា២៥ : ជនណាធ្វើឱ្យរាំងស្ទះ ឬ ប្រឆាំងនឹងការត្រួតពិនិត្យក្នុងការប្រមូលប្រាក់ពន្ធ ឬ ប្រមូលប្រាក់ពិន័យអំពីពន្ធលើទំនិញនាំចេញ ឬ នាំចូល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ៣ ឆ្នាំ ។

មាត្រា២៦ : កម្មាភិបាល បុគ្គលិកគយនិងរដ្ឋាករណាដែលបន្លំលួច កែបំបាត់ប្រាក់ពន្ធ ប្រាក់ពិន័យ ទំនិញ ឬ សម្ភារៈឃាត់ទុក ប្រព្រឹត្តវិតិក្រម ទារសំណូក អ្នកកណ្តាល ក្នុងបទសូក ទទួលសំណូក ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តិនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩ នាសម័យប្រជុំលើកទី១៧ នីតិកាលទី១ ។

ភ្នំពេញ.ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

# តារាង ១_ តារាងពន្ធលើទំនិញនាំចេញ_នាំចូល ដើម្បីអាជីវកម្ម

| ល.រ | ប្រភេទទំនិញ | អត្រាពន្ធ | |
|---|---|---|---|
| | | ខ្ពស់ | អប្បបរមា |
| I | _ ***ទំនិញនាំចូល*** : | | |
| ១ | _ សម្ភារៈវត្ថុធាតុដើម ម៉ាស៊ីនឧបករណ៍ និងគ្រឿងបន្លាស់គ្រឿងសម្ភារៈប្រើការក្នុងផលិតកម្មកសិកម្ម | ៣ភាគរយ _ ៨ភាគរយ | ១ភាគរយ _ ៥ភាគរយ |
| ២ | _ សម្ភារៈវត្ថុធាតុដើម ម៉ាស៊ីនឧបករណ៍ និងគ្រឿងបន្លាស់ គ្រឿងសម្ភារៈ ជំនាងប្រើក្នុងការផលិតឧស្សាហកម្ម វុក្ខកម្ម នេសាទ សាងសង់ គមនាគមន៍ និងដឹកជញ្ជូន សុខាភិបាល វិទ្យាសាស្ត្របច្ចេកទេស.......... | ៥ភាគរយ _ ១៥ភាគរយ | ៣ភាគរយ _ ១០ភាគរយ |
| ៣ | _ ទំនិញប្រើប្រាស់ចាំបាច់ | ៥ភាគរយ _ ១៥ភាគរយ | ៣ភាគរយ _ ១០ភាគរយ |
| ៤ | _ ទំនិញប្រើប្រាស់ធម្មតា ក្នុងប្រទេសផលិតមិនទាន់គ្រប់គ្រាន់ | ២០ភាគរយ _ ៣០ភាគរយ | ១៥ភាគរយ _ ២៥ភាគរយ |
| ៥ | _ ទំនិញប្រើប្រាស់ថ្នាក់ខ្ពស់ ដូចជារថយន្តទេសចរណ៍ ទោចក្រយានយន្ត ម៉ាញ៉េ ទូរទស្សន៍ ស្រា បារី ។ល។ | ៣៥ភាគរយ _ ១០០ភាគរយ | ៣០ភាគរយ _ ៨០ភាគរយ |
| II | _ ***ទំនិញនាំចេញ*** : | | |
| | គ្រប់ប្រភេទទំនិញដែលអនុញ្ញាតឱ្យនាំចេញ | ៥ភាគរយ _ ១០ភាគរយ | ៣ភាគរយ _ ៧ភាគរយ |

បានឃើញ ដើម្បីភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងច្បាប់ ស្តីពីពន្ធលើទំនិញនាំចេញនិងនាំចូល ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩ ។

ភ្នំពេញ.ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩
ជ.រដ្ឋសភា
ប្រធាន
ហត្ថលេខា និង ត្រា : ជា ស៊ីម

## តារាង ២ ៖ តារាងពន្ធលើទំនិញនាំចេញ-នាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

| ល.រ | ប្រភេទទំនិញ | អត្រាពន្ធ |
|---|---|---|
| I | - ***ទំនិញនាំចូល*** : | |
| ១ | - សម្ភារៈវត្ថុធាតុដើម ម៉ាស៊ីន ឧបករណ៍ និង គ្រឿងបន្លាស់ គ្រឿងសម្ភារៈប្រើការក្នុងផលិតកម្មកសិកម្ម........... | ១ភាគរយ - ៥ភាគរយ |
| ២ | - សម្ភារៈវត្ថុធាតុដើម ម៉ាស៊ីន ឧបករណ៍ និង គ្រឿងបន្លាស់ គ្រឿងសម្ភារៈជំនាង ប្រើក្នុងការផលិតឧស្សាហកម្ម រុក្ខកម្ម នេសាទ សាងសង់ គមនាគមន៍ និង ដឹកជញ្ជូន សុខាភិបាល វិទ្យាសាស្ត្របច្ចេកទេស.......... | ៣ភាគរយ - ១០ភាគរយ |
| ៣ | - ទំនិញប្រើប្រាស់ចាំបាច់.............................. | ៣ភាគរយ - ១០ភាគរយ |
| ៤ | - ទំនិញប្រើប្រាស់ធម្មតាក្នុងប្រទេសផលិតមិនទាន់គ្រប់គ្រាន់ | ១៥ភាគរយ - ២៥ភាគរយ |
| ៥ | - ទំនិញប្រើប្រាស់ថ្នាក់ខ្ពស់ ដូចជា រថយន្ត ទេសចរណ៍ ទោចក្រយានយន្ត ម៉ាញ៉េ ទូរទស្សន៍ ស្រា បារី ។ ល ។ | ៣០ភាគរយ - ៨០ភាគរយ |
| II | - ***ទំនិញនាំចេញ*** : | |
| | - គ្រប់ប្រភេទទំនិញ ដែលអនុញ្ញាតឱ្យនាំចេញ | ៣ភាគរយ - ៧ភាគរយ |

បានឃើញ ដើម្បីភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងច្បាប់ ស្តីពីពន្ធលើទំនិញនាំចេញនិងនាំចូល ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩ ។

ភ្នំពេញ.ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៩

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម